# ការចាក់វ៉ាក់សាំង COVID-19 សម្រាប់ទារកនិងកូនក្មេង



## សំណួរ & ចម្លើយសម្រាប់ឪពុកម្តាយនិងអាណាព្យាបាល

ខែ មីនា ឆ្នាំ 2022

Public Health
Seattle & King County

# ហេតុអ្វីបានជាកូនរបស់ខ្ញុំគួរចាក់វ៉ាក់សាំង?

**ការចាក់វ៉ាក់សាំង COVID-19 គឺជាវិធីមួយដ៏ល្អបំផុតដើម្បីការពារកូនរបស់អ្នកឱ្យផុតពីការឈឺដេកពេទ្យឬបង្កឱ្យមានរោគសញ្ញាយូរអង្វែងទៅថ្ងៃក្រោយ។**

ករណីជំងឺ COVID-19 ភាគច្រើនដែលកើតមកលើកូនក្មេងមិនមានបញ្ហាធ្ងន់ធ្ងរទេ ក៏ប៉ុន្តែពេលខ្លះ COVID-19 អាចបណ្ដាលឱ្យកើតជំងឺធ្ងន់ធ្ងរដែរ។ COVID-19 គឺជាជំងឺមួយក្នុងចំណោមជំងឺទាំង 10 ប្រភេទ ដែលបណ្ដាលឱ្យមានការស្លាប់ក្នុងចំណោមកូនក្មេង។ កូនក្មេងក៏អាចមានបញ្ហាសុខភាពយូរអង្វែងទៅថ្ងៃក្រោយដោយសារវីរុសនេះ ដែលត្រូវបានគេហៅថា ជំងឺកូវីដ (COVID) យូរអង្វែង។

# ហេតុអ្វីបានជាកូនរបស់ខ្ញុំគួរចាក់វ៉ាក់សាំង?

ការចាក់វ៉ាក់សាំងឱ្យកូនរបស់អ្នកក៏នឹងការពារសមាជិកក្រុមគ្រួសារនិងមិត្តភក្តិ ជាពិសេសគឺអ្នកដែលអាចមានហានិភ័យខ្ពស់។



# ហេតុអ្វីបានជាកូនរបស់ខ្ញុំគួរចាក់វ៉ាក់សាំង?

**ការចាក់វ៉ាក់សាំងជួយពួកកូនក្មេង។** នៅពេលក្មេងចាក់វ៉ាក់សាំងគ្រប់ចំនួនហើយ ពួកគេអាចធ្វើអ្វីៗដែលពួកគេពេញចិត្ត ដូចជា ចូលរួមពិធីជប់លៀងបុណ្យកំណើត លេងកីឡា និងចំណាយពេលវេលានៅក្នុងអគារជាមួយមិត្តភក្តិនិងក្រុមគ្រួសារ។



# តើថ្នាំវ៉ាក់សាំងសម្រាប់កូនក្មេងមានសុវត្ថិភាពនិងប្រសិទ្ធភាពឬទេ?

មាន។ រដ្ឋបាល FDA បានសម្រេចថា **មិនមានការព្រួយបារម្ភណ៍ខ្លាំងអំពីសុវត្ថិភាព**នៃថ្នាំវ៉ាក់សាំងទេ យោលទៅតាមការសិក្សានៅក្នុងមន្ទីរពិសោធ ហើយវាមានប្រសិទ្ធភាពជាង 90% ក្នុងការការពារកូនក្មេងឱ្យផុតពីការឈឺធ្ងន់ធ្ងរដោយសារជំងឺកូរ៉ូណា។

កូនក្មេងក៏នៅអាចកើតជំងឺកូវីដ (COVID) ដែរ ក្រោយពីបានចាក់វ៉ាក់សាំងរួច ក៏ប៉ុន្តែថ្នាំ**វ៉ាក់សាំងការពារបញ្ហាធំជាងគេគឺ៖ ការពារឱ្យផុតពីការឈឺដេកពេទ្យ បញ្ហាសុខភាពធ្ងន់ធ្ងរ និងការស្លាប់។**

# ខ្ញុំពិបាកធ្វើដំណើរទៅកាន់ទីតាំងចាក់វ៉ាក់សាំង។ តើមានអ្វីជួយខ្ញុំឬទេ?

- **ការធ្វើដំណើរ៖** ប្រសិនបើអ្នកត្រូវការការជួយជូនដំណើរ សូមអ៊ីមែលមក publichealthaccommodations@kingcounty.gov ឬទូរស័ព្ទមកលេខ 206-477-3977។
- **ការបកប្រែភាសា៖** ប្រសិនបើអ្នកត្រូវការសេវាកម្មបកប្រែភាសា សូមទូរស័ព្ទមកមណ្ឌលទទួលបន្ទុកខាង COVID-19 របស់ King County ៖ 206-477-3977 ចាប់ពីម៉ោង 8 ព្រឹក-5 ល្ងាច។ សូមប្រាប់ភាសារបស់អ្នកនៅពេលគេភ្ជាប់ទូរស័ព្ទ។
- **ការដឹកជញ្ជូន៖** ប្រសិនបើអ្នកត្រូវការឱ្យគេជូនដំណើរទៅណាត់ជួបចាក់វ៉ាក់សាំង សូមទូរស័ព្ទមកមណ្ឌលដឹកជញ្ជូន តាមរយៈលេខ៖ (425) 943-6760 ចាប់ពីម៉ោង 8:30 ព្រឹក – 4:00 រសៀល។ ឬចូលទៅគេហទំព័រ www.FindARide.org ។